# កិច្ចព្រមព្រៀងស្តីពីគណនីមានកំរិតនៃកម្មវិធី CALFRESH ភាគ A

| ឈ្មោះសំណុំរឿង ៖ | លេខសំណុំរឿង ៖ |
|---|---|
| ឈ្មោះអ្នកធ្វើការខោនធី ៖ | លេខអ្នកធ្វើការ ៖ |

## អាន ហើយចុះហត្ថលេខាសង្ខេបលើវិធាននិមួយៗខាងក្រោម ។

| ហត្ថលេខាសង្ខេប | **ខ្ញុំយល់ ៖** |
|---|---|
| | ថវិការត្រូវតែរក្សាទុកនៅក្នុងស្ថាប័នហិរញ្ញវត្ថុ ដូចជាធនាគារ, សហជីពឥណទាន, ស្ថាប័នសន្សំ និងកម្ចីជាដើម រាល់ថវិកាទាំងឡាយ នៅក្នុងគណនីមានកំរិតរបស់ខ្ញុំត្រូវតែដាក់ដោយឡែកពីគណនីដទៃៗទៀត ។ |
| | ខ្ញុំត្រូវតែផ្តល់ភ័ស្តុតាងនៃព័ត៌មានអំពីគណនី ។ ឧទាហរណ៍ខ្លះៗនៃព័ត៌មានអំពីគណនី មានរួមដូចជា ៖<br>● របាយការណ៍ធនាគារ ឬបង្កាន់ដៃពីធនាគារណាមួយ, សហជីពឥណទាន ជាដើម ដែលមានបង្ហាញពីឈ្មោះ និងអាសយដ្ឋានរបស់ធនាគារ<br>● គ្រប់គណនីសមតុល្យ និងសកម្មភាពនានាតាំងពីកាលបរិច្ឆេទដែលអ្នកបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីគណនីមានកំរិត<br>● ឈ្មោះ(ច្រើន) នៅក្នុងគណនី (ច្រើន) |
| | ខ្ញុំយល់ថាឧទាហរណ៍ខ្លះៗនៃភ័ស្តុតាងនៃរបៀបខ្ញុំចំណាយ ថវិកាដែលដកចេញពីគណនីមានកំរិត (ច្រើន) មានរួមបញ្ចូលដូចខាងក្រោម ៖<br>● ក្រដាសសែកបានលុបចោល<br>● សេចក្តីថ្លែងការណ៍ (ច្រើន) មានចុះហត្ថលេខាពីអ្នកផ្តល់ការបំរើ (ច្រើន) ជារបស់របរ ឬសេវា ដែលមានបង្ហាញនូវប្រភេទ និងចំនួននៃការចំណាយ (ច្រើន) ដែលបានបង់ប្រាក់<br>● បង្កាន់ដៃ (ច្រើន) |
| | កិច្ចព្រមព្រៀងស្តីពីគណនីមានកំរិតនេះ បញ្ឈប់ ៖<br>● ពេលណាខ្ញុំមិនផ្តល់ឲ្យអ្នកធ្វើការនូវភ័ស្តុតាងអំពីគណនីមានកំរិត<br>● ពេលណាគ្រួសាររបស់ខ្ញុំឈប់ទទួលជំនួយពីកម្មវិធី CalFresh<br>● ពេលណាគណនីមានកំរិតត្រូវបានបិទ<br>● បើសិនជាច្បាប់ស្តីពីគណនីមានកំរិតត្រូវប្តូរ |
| | មិនមានការកំរិតពីចំនួនអតិបរិមានៃការសន្សំនៅក្នុងគណនីមានកំរិត ។ ខ្ញុំអាចមានគណនីមានកំរិតលើសពីមួយ ហើយថវិកានៅក្នុងគណនីមានកំរិតនោះមិនត្រូវរាប់ប្រឆាំងនិងធនធានកំរិតរបស់គ្រួសារខ្ញុំទេ ។ |
| | បើសិនជាជំនួយពីកម្មវិធី CalFresh របស់ខ្ញុំត្រូវបញ្ឈប់ដោយមូលហេតុណាមួយ ហើយបើខ្ញុំត្រូវដាក់ពាក្យសុំជំនួយពីកម្មវិធី CalFresh ឡើងវិញ ហើយមានការអោក់អួលក្នុងការទទួលជំនួយ ធនធានដែលអាចរាប់បានសរុបរបស់ខ្ញុំ រួមទាំងប្រាក់អ្វីក៏ដោយនៅក្នុងគណនីមានកំរិត (ច្រើន) មិនអាចលើសពីចំនួន $2,000/$3,250 ធនធានមានកំរិត ។ ខ្ញុំត្រូវតែមានការព្រមព្រៀងស្តីពីគណនីមានកំរិតថ្មីមួយឡើងវិញនៅពេលដាក់ពាក្យសុំដើម្បីចាប់ផ្តើមគណនីមានកំរិតថ្មីមួយទៀត ។ កិច្ចព្រមព្រៀងស្តីពីគណនីមានកំរិតគឺតំរូវឲ្យមាន បើសិនជាមានការអោក់អួលក្នុងការទទួលជំនួយ ។ |
| | បើសិនជាថវិកាពីគណនីមានកំរិត (ច្រើន) របស់ខ្ញុំ ត្រូវបានដក ហើយមិនត្រូវបានចំណាយ ទៅលើការចំណាយដែលអនុញ្ញាត ទោះជាពេលដែលខ្ញុំត្រូវតែចំណាយសំរាប់មរណៈភាព ឬភាពបន្ទាន់អាសន្នដែលគំរាមកំហែងដល់ជីវិតក៏ដោយ ចំនួនដែលបានដកនោះនឹងត្រូវរាប់បញ្ចូលនិងធនធានកំរិត ហើយ ខោនធីនឹងត្រូវធ្វើការវាយតំលៃធនធានទាំងអស់ឡើងវិញ ។ |
| | សេចក្តីត្រូវការឲ្យធនធាននានានៅជិតកំរិត $2,000 នៃធនធានកំរិតរបស់ខ្ញុំ ($3,250 បើសិនជាយ៉ាងហោចណាស់មានសមាជិកក្រុមគ្រួសារម្នាក់ដែលពិការ/អាយុ 60 ឆ្នាំ ឬចាស់ជាង) សំរាប់ ភាពបន្ទាន់អាសន្ន ឬការចំណាយនានាផ្សេងទៀតមុនខ្ញុំចាប់ផ្តើមគណនីមានកំរិត ។ |
| | បើសិនជាខ្ញុំរាយការណ៍ពីប្រាក់ចំណូលហើយសមាជិកក្រុមគ្រួសារប្រែប្រួលពាក់កណ្តាលឆ្នាំ ហើយដកថវិកានៅក្នុងរយៈពេលពាក់កណ្តាលឆ្នាំ ខ្ញុំត្រូវបានគេតំរូវឲ្យរាយការណ៍នូវការដកនោះនៅលើរបាយការណ៍ប្រាក់ចំណូលលើកក្រោយ (SAR 7) ឬនៅពេលដែលត្រូវធ្វើការបញ្ជាក់ពេលទទួលជំនួយឡើងវិញ ។ បើសិនជាខ្ញុំមិនមែនជាក្រុមគ្រួសាររាយការណ៍ពាក់កណ្តាលឆ្នាំ ខ្ញុំត្រូវតែរាយការណ៍នៃការដកប្រាក់នោះក្នុងរវាង 10 ថ្ងៃ ចាប់ពីថ្ងៃដែលបានដកប្រាក់ ។ |
| | ការប្រាក់ដែលបានពីគណនីមានកំរិតរបស់ខ្ញុំ ត្រូវតែដាក់កក់ដោយផ្ទាល់ចូលក្នុងគណនី (ច្រើន) ។ បើសិនជាការប្រាក់នោះត្រូវបានផ្ញើមកខ្ញុំ ខ្ញុំត្រូវតែដាក់វាបញ្ចូលទៅក្នុងគណនីមានកំរិតរបស់ខ្ញុំ ។ |
| | ប្រាក់ដែលសន្សំក្នុងគណនីមានកំរិតអាចចំណាយបានតែសំរាប់ការចំណាយអាចអនុញ្ញាតដែលទាក់ទងដោយផ្ទាល់ទៅនឹង ៖<br>● ការទិញផ្ទះដែលខ្ញុំនឹងរស់នៅទីនោះ<br>● ការចាប់ផ្តើមមុខរបររអាជីវកម្មថ្មី<br>● ការអប់រំ ឬហ្វឹកហ្វឺនការងារសំរាប់ម្ចាស់គណនី និងអ្នកនៅក្រោមបន្ទុករបស់គេ (ច្រើន) |

## ការបញ្ជាក់

ខ្ញុំបានអានទំព័រក្របខាងលើ ។ ខ្ញុំយល់ពីវិធាននានា និងយល់ពីការទទួលខុសត្រូវរបស់ខ្ញុំដូចដែលខ្ញុំបានចុះហត្ថលេខាសង្ខេបខាងលើសំរាប់ការចាប់ផ្តើម និងរក្សាគណនីមានកំរិត និងសេចក្តីត្រូវការឲ្យធនធាននានានៅជិតកំរិត $2,000 នៃធនធានកំរិត ឬ $3,250 (បើសិនជាយ៉ាងហោចណាស់មានសមាជិកក្រុមគ្រួសារម្នាក់ដែលពិការ/អាយុ 60 ឆ្នាំ ឬចាស់ជាង) សំរាប់ ភាពបន្ទាន់អាសន្ន ឬការចំណាយនានាផ្សេងទៀត មុនខ្ញុំចាប់ផ្តើម គណនីមានកំរិត មួយ ។ ខ្ញុំនឹងសួរអ្នកធ្វើការរបស់ខ្ញុំ បើសិនជាខ្ញុំមិនច្បាស់ពីអ្វីដែលជាការចំណាយអាចអនុញ្ញាតបាន, ភ័ស្តុតាងអ្វីដែលត្រូវការ ឬពេលណាដែលភ័ស្តុតាងត្រូវផ្តល់ទៅឲ្យខោនធី ។

| ហត្ថលេខា ឬគូសសញ្ញាជាមេគ្រួសារ ឬអ្នកតំណាងស្របច្បាប់ | កាលបរិច្ឆេទ |
|---|---|
| ហត្ថលេខា ឬគូសសញ្ញាជាកសិណសាក្សី និង/ឬ អ្នកបកប្រែភាសា | កាលបរិច្ឆេទ |